**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ ០៤៣ ណ.ខ.ឃ

# សេចក្តីជូនដំណឹង
# ស្តីពី មហាសន្និបាតភាគហ៊ុនិក លើកទី១១
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ជ្រាបថា៖ រ.ទ.ស.ភ នឹងរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី១១ **នៅថ្ងៃសុក្រ ៧កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧** ត្រូវនឹង**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣** ចាប់ពីម៉ោង **៨:០០នាទីព្រឹក** តាមប្រព័ន្ធអនឡាញ (ZOOM) ដែលមានរបៀបវារៈដូចខាងក្រោម៖

១. ការចុះវត្តមាន
២. ប្រកាសហេតុ
៣. បទបង្ហាញស្តីពី៖
   ក- របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២២
   ខ- ទិសដៅអាជីវកម្ម ឆ្នាំ២០២៣
   គ- សំណួរ-ចម្លើយ
៤. កម្មវិធីបោះឆ្នោត
   ក- បោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក
   ខ- បោះឆ្នោតអនុម័តលាភការរបស់ក្រុមប្រឹក្សាភិបាល
៥. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណរបស់ប្រធានគណៈអធិបតី

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ (កាលបរិច្ឆេទកំណត់ទុកនៃមហាសន្និបាតភាគហ៊ុនិក លើកទី១១) ត្រូវបញ្ជាក់ការចូលរួមជាមួយ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) នៅរៀងរាល់ថ្ងៃធ្វើការ **ចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣** ដល់ **ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣** ចាប់ពីម៉ោង **៨:០០នាទី** ដល់ម៉ោង **១៦:៣០នាទី**។

☆ **បញ្ជាក់ ៖**

១. ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់ រ.ទ.ស.ភ ប៉ុន្តែមិនបានធ្វើការបញ្ជាក់ការចូលរួមរបស់ខ្លួនជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើនេះនឹងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់ រ.ទ.ស.ភ នោះទេ។



អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

២. ភាគហ៊ុនិកអាចចូលរួមមហាសន្និបាតនេះ ដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ (អ្នកតំណាង)។ ភាគហ៊ុនិកដែលចូលរួមតាមរយៈអាណត្តិគាហកៈ ត្រូវតែងតាំងអាណត្តិគាហកៈរបស់ខ្លួនតាមទម្រង់ "លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)" ដែលផ្តល់ដោយ រ.ទ.ស.ភ ឬ ធនាគារ អេស៊ីលីដា ភីអិលស៊ី និង**ត្រូវផ្តល់លិខិតតែងតាំងអាណត្តិគាហកៈនេះជូន រ.ទ.ស.ភ តាមរយៈសារអេឡិកត្រូនិក** ir@ppwsa.com.kh **យ៉ាងយូរត្រឹមថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣** ដើម្បីចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់ រ.ទ.ស.ភ។

៣. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមរក្សាសិទ្ធិកែប្រែកម្មវិធី របៀបវារៈ និងទម្រង់អនឡាញនៃមហាសន្និបាតភាគហ៊ុនិកលើកទី១១ ក្នុងករណីមានការចាំបាច់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

- **ធនាគារ អេស៊ីលីដា ភីអិលស៊ី**

  អាសយដ្ឋាន: អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

  - **លោក ហួត សុភី** ប្រធានផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ : (៨៥៥)១៥ ៩០០ ៥៣៨
    អ៊ីម៉ែល : huot.sophy@acledabank.com.kh
  - **លោក កែន រិទ្ធពុទ្ធា** អ្នកឯកទេសបឋមប្រតិបត្តិការ RTP
    ទូរស័ព្ទ : (៨៥៥)១៥ ៨០០ ៦៦៣
    អ៊ីម៉ែល : ken.rithputhea@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារង្សី** បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ RTP
    ទូរស័ព្ទ : (៨៥៥) ៦១ ២៨៧ ៧៦៦
    អ៊ីម៉ែល : op.rtp@acledabank.com.kh

- **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
  - អាសយដ្ឋាន : លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ទូរស័ព្ទដៃ : (៨៥៥)៣១ ៣២២ ៦៣៤៥
  - អ៊ីម៉ែល : ir@ppwsa.com.kh

ថ្ងៃ ព្រហស្បតិ៍ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣
**ជ.គណៈកម្មការរៀបចំ និងដំណើរការ**
**មហាសន្និបាតភាគហ៊ុនិក លើកទី១១**
**ប្រធាន**

**ឡុង ណារ៉ូ**

**ចម្លងជូន៖**
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យផ្ទៃក្នុង រ.ទ.ស.ភ

  "មេត្តាជ្រាប"
- ឯកសារ-កាលប្បវត្តិ



អគារ ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ៖ (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh